COUNTY OF LOS ANGELES
Public Health

# ពិធីការបើកឡើងវិញសម្រាប់ កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ៖ ឧបសម្ព័ន្ធ L

## មានប្រសិទ្ធិភាពចាប់ពីម៉ោង៖ ម៉ោង 12:01 អធ្រាត្រថ្ងៃថ្ងៃព្រហស្បតិ៍ទី6 ខែឧសភា ឆ្នាំ 2021

**បច្ចុប្បន្នភាពថ្មីៗ៖** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)
**5/5/2021:** បានធ្វើបច្ចុប្បន្នភាពដើម្បីបង្កើនការកំណត់ចំនួនមនុស្សអតិបរមា %50 នៃទីតាំងទាំងមូល ដោយផ្អែកលើដែនកំណត់នៃទំហំអាគារ ឬបទប្បញ្ញត្តិអគ្គីភ័យ។ អាងទឹកក្តៅនៅខាងក្នុងអគារ សូណា និងបន្ទប់ចំហាយទឹកអាចបើកឡើងវិញសម្រាប់ប្រើប្រាស់។

អត្រាករណី ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់មានការថយចុះខ្លះ ហើយហាក់ដូចជាមានស្ថេរភាព ប៉ុន្តែជំងឺ COVID-19 នៅតែមានហានិភ័យ (risk) ខ្ពស់សម្រាប់សហគមន៍ និងតម្រូវឲ្យប្រជាជន និងអាជីវកម្មទាំងអស់មានការប្រុងប្រយ័ត្ន និងកែប្រែប្រតិបត្តិការ និងសកម្មភាពដើម្បីកាត់បន្ថយហានិភ័យ (risk) នៃការរីករាលដាល។

ដោយសារខោនធី Los Angeles ចូលក្នុង “លំដាប់ថ្នាក់ពណ៌លឿង (Yellow Tier)” នៃក្របខ័ណ្ឌផែនការដើម្បីសេដ្ឋកិច្ចមានសុវត្ថិភាពជាងមុន (Blueprint for a Safer Economy) របស់រដ្ឋ ពិធីការនេះត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីលើកលែងការរឹតបន្តឹងដែលជាក់លាក់សម្រាប់សកម្មភាពក្នុងមូលដ្ឋានមួយចំនួន។ កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ គួរបន្តប្រតិបត្តិការប្រកបដោយការប្រុងប្រយ័ត្ន និងគោរពតាមល័ក្ខខ័ណ្ឌតម្រូវនៅក្នុងពិធីការនេះ ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ល័ក្ខខ័ណ្ឌតម្រូវខាងក្រោមគឺជាក់លាក់សម្រាប់កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ ការហាត់យ៉ូហ្គា និងស្ទូឌីយ៉ូរាំ ការហាត់ប្រាណ 1:1 និងការឡើងជញ្ជាំង (ជារួមត្រូវបានហៅថា “កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ”)។ បន្ថែមលើល័ក្ខខ័ណ្ឌដែលបានដាក់លើអាជីវកម្មជាក់លាក់ទាំងនេះដោយអភិបាលរដ្ឋ អាជីវកម្មប្រភេទទាំងនេះ ក៏ត្រូវតែអនុលោមតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងពិធីការបើកឡើងវិញសម្រាប់កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណផងដែរ។

កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណអាចបើកឡើងវិញសម្រាប់ប្រតិបត្តិការខាងក្នុងអគារដោយមានកំណត់ចំនួនមនុស្ស។ ប្រតិបត្តិការខាងក្នុងអគារនៅតាមកន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ ត្រូវបានកម្រិតចំនួនមនុស្សត្រឹម 50% ដោយផ្អែកលើច្បាប់សំណង់ ឬច្បាប់អគ្គីភ័យជាធរមាន ហើយអាចបន្តបើកទ្វារដល់សាធារណជនសម្រាប់ប្រតិបត្តិការខាងក្រៅអគារ។ ដោយសារប្រតិបត្តិការហាត់ប្រាណខាងក្រៅអគារមានហានិភ័យ (risk) នៃការចម្លងទាបជាងបើប្រៀបធៀបជាមួយប្រតិបត្តិការខាងក្នុងអគារ កន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណត្រូវបានលើកទឹកចិត្តឲ្យបន្តផ្តល់អទិភាពលើសេវាកម្មខាងក្រៅអគារ។ សម្រាប់ប្រតិបត្តិការទាំងខាងក្នុងអគារ និងខាងក្រៅអគារ បុគ្គលិក និងភ្ញៀវទាំងអស់ត្រូវតែពាក់ម៉ាស់សមស្របនៅគ្រប់ពេលវេលា លើកលែងតែពេលហែលទឹក។ សម្រាប់ព័ត៌មានបន្ថែមអំពីម៉ាស់ សូមមើលគេហទំព័រម៉ាស់ជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles (LAC DPH) នៅ http://ph.lacounty.gov/masks។

អាងទឹកក្តៅនៅខាងក្នុងនិងខាងក្រៅអគារ សូណានៅខាងក្នុងនិងបន្ទប់ចំហាយទឹកអាចបើកឱ្យដំណើរការវិញហើយ។ អាងទឹកក្តៅនៅខាងក្នុងនិងខាងក្រៅអគារអាចបើកឲ្យប្រើសម្រាប់ក្រុមគ្រួសារឬនៅពេលដែលអាចរក្សាគំលាត 6 ហ្វីត ចំពោះសមាជិកដែលមិនមែនគ្រួសារ។ បន្ទប់សូណា និងបន្ទប់ចំហាយទឹកត្រូវតែកំណត់ចំនួនមនុស្សអតិបរមា %50 នៃទីតាំងទាំងមូល។ អាងហែលទឹកនៅខាងក្នុង និងខាងក្រៅអគារអាចបើកឡើងវិញសម្រាប់ការប្រើប្រាស់ជាធម្មតា។ អាងហែលទឹកទាំងអស់ត្រូវតែអនុលោមតាមពិធីការសម្រាប់អាងហែលទឹកសាធារណៈរបស់ LACDP

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំ សម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍កន្លែងធ្វើការ និងការអនុវត្តដើម្បីការពារសុខភាពបុគ្គលិក

(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ

(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណជន

(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ ស្របពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**អាជីវកម្មទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ______________________________

**អាសយដ្ឋានទីកន្លែង៖** ______________________________

**ចំនួនមនុស្សអតិបរមា តាមច្បាប់អគ្គីភ័យ៖** ______________________________

**ប្រហាក់ប្រហែលទំហំទីធ្លាគិតសរុបជាហ្វីតការ៉េដែលបើកដល់សាធារណជន៖** ______________________________

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពប្រចាំកាយ) ត្រូវបានកំណត់ការ ងារដែលអាចធ្វើការពីផ្ទះគ្រប់ពេលដែលអាចធ្វើបាន និងគួរពិភាក្សាអំពីក្តីកង្វល់នានាជាមួយអ្នកផ្តល់សេវាសុខ ភាព ឬសេវាកម្មសុខភាពការងាររបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តបានសមស្របអំពីការត្រឡប់ទៅកន្លែងធ្វើការវិញ។
- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះ។
- ❑ ម្យ៉ាងវិញទៀត កាលវិភាគឆ្លាស់វេនគ្នា ឬប្តូរវេនគ្នាត្រូវបានអនុវត្តដើម្បីបង្កើនការរក្សាគំលាតរាងកាយជាអតិបរមា។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់ថាកុំមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
- ❑ ការត្រួតពិនិត្យការចូល ត្រូវបានធ្វើឡើងមុនពេលបុគ្គលិក អ្នកលក់ បុគ្គលិកដឹកជញ្ជូន និងនរណាម្នាក់ដែលផ្តល់សេវាកម្មនៅនឹងកន្លែងអាចចូលមកក្នុងកន្លែងធ្វើការ ដោយយោងទៅតាម[ការណែនាំអំពីការត្រួតពិនិត្យការចូល]របស់ LACDPH។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យ ពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក និងឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬក៏អត់។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់បន្ទាប់ពីបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅ កន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
  - ○ ការពិនិត្យឃើញអវិជ្ជមាន (គ្មានបញ្ហា)។ បើសិនជាបុគ្គលមិនមានរោគសញ្ញា និងមិនបានប៉ះពាល់ជាមួយករណីដែលគេដឹងថាជាករណីជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលសម្រាប់ថ្ងៃនោះបាន។
  - ○ ការពិនិត្យឃើញវិជ្ជមាន (មានបញ្ហា)៖
    - ▪ បើសិនជាបុគ្គលមិនបានចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹង[1]ជំងឺ COVID-19 និងមានការប៉ះពាល់ជាមួយករណីដែលគេដឹងថាមានជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោម

---

[1] បុគ្គលដែលត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួនគឺ គិតចាប់ពីពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំងពីរដូស (រួមមានPfizer -BioNTech ឬ Moderna) ឬ ពីរ (2) សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃ ប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen) ។

សេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូល ឬធ្វើការនៅទីវាលបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗ ដើម្បីនៅដាច់ពីគេនៅផ្ទះ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ពីគេ ដែលមាននៅ ph.lacounty.gov/covidquarantine។

- បើសិនជាបុគ្គលកំពុងចេញរោគសញ្ញាណាមួយនៃរោគសញ្ញាដែលបានកត់សម្គាល់ខាងលើ ឬកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែកនាពេលបច្ចុប្បន្ន ពួកគេមិនអាចចូល ឬធ្វើការនៅទីវាលបានទេ នឹងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែក ដែលមាននៅ ph.lacounty.gov/covidisolation។

- ❑ ព័ត៌មានអំពីអត្ថប្រយោជន៍នៃការសុំច្បាប់ឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធី រដ្ឋាភិបាលដែលគាំទ្រការសុំច្បាប់ឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោមច្បាប់ឈប់សម្រាកដោយជំងឺCOVID-19បន្ថែមនៅឆ្នាំ 2021។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យមានការធ្វើចត្តាឡីស័កដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬ ក៏អត់ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈនៅលើ ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles តាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬតាមអនឡាញនៅ www.redcap.link/covidreport ។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាក្រុម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែល ជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាក្រុមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។ នាយកដ្ឋានសុខភាពសាធារណៈនឹងត្រូវការ ការសហការភ្លាមៗរបស់ទីកន្លែងដើម្បីកំណត់ថាតើចង្កោមករណីនេះបង្កើតជាការផ្ទុះជំងឺ COVID-19 ឬក៏អត់។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃទទួលបានម៉ាស់សម្រាប់ដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រម៉ាស់ជំងឺ COVID-19 របស់ LAC DPH នៅ http://ph.lacounty.gov/masks។ បុគ្គលិកត្រូវតែពាក់ម៉ាស់នេះគ្រប់ពេលវេលាក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរម៉ាស់ ត្រូវពាក់សន្ទះបាំងមុខដែលមានក្រណាត់រំពឹតែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាស្ថានភាពសុខភាពរបស់ពួកគេអនុញ្ញាតឲ្យធ្វើដូច្នេះ។ ក្រណាត់រុំដែលមានទម្រង់រឹតតឹងខាងក្រោមចង្កាគឺជាការពេញនិយម។ មិនត្រូវប្រើម៉ាស់ដែលមានរន្ធមួយផ្លូវឡើយ។ ម៉ាស់ដែលរឹតត្បិតលំហូរខ្យល់ក្រោមការបញ្ចេញកម្លាំងខ្លាំង (ដូចជាម៉ាស់ N-95) គឺមិនត្រូវបានណែនាំសម្រាប់ការហាត់ប្រាណទេ។
- ❑ បុគ្គលិកទាំងអស់ត្រូវតែពាក់ម៉ាស់នៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជន ដែលបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់ តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិកខណៈពេលដែលឈរ ត្រូវបានបដិសេធចោល ។
- ❑ ដើម្បីធ្វើឲ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានរារាំងមិនឲ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគំលាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក វាជាការប្រសើរដែលត្រូវធ្វើដូច្នោះនៅខាងក្រៅអគារនិងឆ្ងាយពីអ្នកដទៃ បើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹកនៅបន្ទប់តូច ឬស្ថានីយការងារ គឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្តល់ជូនគំលាតកាន់តែធំ និងរបាំងរវាងបុគ្គលិក។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគំលាតរវាងបុគ្គលិកត្រូវបានបង្កើនឡើងជាអតិបរមានៅក្នុងបន្ទប់ ឬ

ទីកន្លែងទាំងឡាយដែលប្រើប្រាស់ដោយបុគ្គលិកសម្រាប់ការបរិភោគអាហារ និង/ឬសម្រាក។ ចំណុចនេះសម្រេចបានដោយ៖

- ○ បិទប្រកាសចំនួនមនុស្សអតិបរមា ដែលត្រូវគ្នានឹងការអនុញ្ញាតឲ្យមានគំលាតយ៉ាងតិចប្រាំមួយហ្វីត រវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក និង
- ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
- ○ ដាក់តុឃ្លាតពីគ្នាយ៉ាងហោចណាស់ប្រាំបីហ្វីត និងធានាថាមានគំលាតប្រាំមួយហ្វីតចន្លោះកៅអី ដោយដកកៅអី ឬបិទបង់ស្ទិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋដើម្បីធានាបាននូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នាជាអប្បបរមា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគំលាតរាងកាយឡើយ។

- ❑ បុគ្គលិកដែលត្រូវតែស្ថិតក្នុងគំលាត 6 ហ្វីតជានិច្ចពីភ្ញៀវ ឬបុគ្គលិករួមការងារដែលមិនពាក់ម៉ាស់ ត្រូវតែពាក់របាំងទីពីរ (ឧ. សន្ទះបាំងមុខឬវ៉ែនតាសុវត្ថិភាព) បន្ថែមលើម៉ាស់។ បុគ្គលិកទាំងអស់គួរកាត់បន្ថយរយៈពេលដែលចំណាយក្នុងគំលាតប្រាំមួយហ្វីតពីភ្ញៀវ ជាអប្បបរមា។របាំងមុខគឺជាជម្រើសរបស់បុគ្គលិកពេលដែលពួកគេមានបង្ហាញភស្តុតាងដែលអាចទទួលយកបានអំពីការចាក់វ៉ាក់សាំងពេញលេញដល់និយោជករបស់ពួកគេ ហើយការពាក់ម៉ាស់នៅតែទាមទារឱ្យអនុវត្ត។ សម្រាប់បុគ្គលិកដែលបានទទួលថ្នាំបង្ការពេញលេញដែលបានបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញរបស់ពួកគេប្រឆាំងនឹងជំងឺ COVID-19 ហើយជ្រើសរើសមិនពាក់របាំងមុខ និយោជកគួរតែបង្កើត និងរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលឯកសារដែលបុគ្គលិកម្នាក់ៗបានបង្ហាញភស្តុតាងដែលអាចទទួលយកបានជាភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ។ និយោជកមិនចាំបាច់រក្សាទុកច្បាប់ចម្លងនៃភស្តុតាងការចាក់វ៉ាក់សាំងពេញលេញដែលបានបង្ហាញនោះទេ។
  - ○ បុគ្គលដែលត្រូវបានគេចាត់ទុកថាជាការចាក់វ៉ាក់សាំងប្រឆាំងមេរោគ COVID-19គ្រប់ចំនួនគឺគិតចាប់ពី ច្រើនជាង 2≤សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំង) រួមមាន Pfizer -BioNTechឬ (Modernaឬច្រើនជាង2≤ សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃ ប្រភេទដូសតែមួយដងរួចរាល់ហើយ (Johnson and Johnson [J&J]/Janssen ប្រភេទ)។
  - ○ ខាងក្រោមនេះគឺអាចទទួលយកបានសម្រាប់បុគ្គលិកដោយគ្រាន់តែបង្ហាញទៅនិយោជិករបស់ពួកគេ ជាភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19៖ ប័ណ្ណចាក់វ៉ាក់សាំង (ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន) ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬ រូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងពេញលេញពីមណ្ឌលថែទាំសុខភាព (ដែលរួមមានឈ្មោះអ្នកដែលបានចាក់ថ្នាំបង្ការ និងបញ្ជាក់ថាបុគ្គលនោះបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19)។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យលាងសម្អាត ឬផ្លាស់ប្តូរម៉ាស់របស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ស្ថានីយការងារទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិចប្រាំមួយហ្វីត។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគយ៉ាងហោចណាស់មួយថ្ងៃម្តង ទៅតាមកាលវិភាគដូចខាងក្រោម៖
  - ○ បន្ទប់សម្រាក ______________________________
  - ○ បន្ទប់ទឹក ______________________________
  - ○ ផ្សេងទៀត ______________________________
- ❑ ធ្វើឲ្យប្រាកដថាបុគ្គលិកបណ្តោះអាសន្ន ឬបុគ្គលិកកិច្ចសន្យានៅទីកន្លែង ក៏ត្រូវបានបណ្តុះបណ្តាលសមស្របនៅក្នុងគោលនយោបាយទប់ស្កាត់ជំងឺ COVID-19 និងមានគ្រឿងផ្គត់ផ្គង់ និង PPE ដែលចាំបាច់។ ពិភាក្សាអំពីទំនួលខុសត្រូវទាំងនេះជាមុនជាមួយអង្គភាពដែលផ្គត់ផ្គង់បុគ្គលិកបណ្តោះអាសន្ន និង/ឬបុគ្គលិកកិច្ចសន្យា។
- ❑ ម៉ាស់ត្រូវបានតម្រូវ នៅពេលបុគ្គលិកស្ថិតនៅជិតអ្នកដទៃ។ បុគ្គលិកត្រូវតែមានម៉ាស់រួចជាស្រេច និងពាក់វានៅក្នុង អគារហាត់ប្រាណ ការិយាល័យ ឬយានយន្តដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន នៅពេលធ្វើដំណើរជាមួយអ្នកដទៃ។ ម៉ាស់ មានសារៈសំខាន់ជាពិសេស បើសិនជាមិនអាចរក្សាគំលាតរាងកាយនៅក្នុងការងារបាន (ឧទាហរណ៍

គ្រូបង្វឹកផ្ទាល់ខ្លួននិងបុគ្គលិកដែលជួយសមាជិកហាត់ប្រាណ)។ មិនត្រូវប្រើម៉ាស់រួមគ្នាឡើយ។ និយោជកត្រូវបានតម្រូវឲ្យផ្ដល់ម៉ាស់ដល់បុគ្គលិកទាំងអស់។

- ☐ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

  ______________________________________________

- ☐ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ______________________________________________

- ☐ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ☐ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- ☐ កម្មករនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ ការប្រើប្រាស់រួមគ្នានូវវត្ថុដែលបានប៉ះរួច ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ☐ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។
- ☐ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

  ______________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

- ☐ ប្រតិបត្តិការខាងក្នុងអគារ។ ប្រតិបត្តិការកន្លែងហាត់ប្រាណ និងអាជីវកម្មហាត់ប្រាណ ដែលត្រូវបានផ្ដល់ជូននៅខាងក្នុងអគារត្រូវបានដាក់កម្រិតត្រឹម 50% នៃសមត្ថភាពផ្ទុកមនុស្សអតិបរមានៅក្នុងអគាររបស់ទីកន្លែងដោយផ្អែកលើច្បាប់សំណង់ ឬច្បាប់អគ្គិភ័យជាធរមាន។ការកំណត់ចំនួននៃទីតាំងនេះអនុវត្តចំពោះបន្ទប់នីមួយៗនៅក្នុងកន្លែងហាត់ប្រាណ ឬទីតាំងអាជីវកម្មហាត់ប្រាណរួមមានបន្ទប់ផ្លាស់សម្លៀកបំពាក់ សូណា បន្ទប់ចំហុយ និងបន្ទប់ដាក់សម្ភារៈ។
  - ○ ចំនួនភ្ញៀវអតិបរមានៅក្នុងទីកន្លែងត្រូវបានដាក់កម្រិតត្រឹម៖ ______________________
- ☐ ប្រតិបត្តិការខាងក្រៅអគារ។ ចំនួនមនុស្សនៅទីធ្លាខាងក្រៅអគារត្រូវមានកម្រិតមួយដែលអនុញ្ញាតឲ្យបុគ្គលិកនិងភ្ញៀវទាំងអស់រក្សាគំលាតរាងកាយយ៉ាងតិច 6 ហ្វីតពីគ្នានៅគ្រប់ពេលវេលា។
- ☐ រចនាសម្ព័ន្ធ និងទីធ្លាខាងក្រៅអគារ។ ប្រតិបត្តិការខាងក្រៅអគារ អាចត្រូវបានធ្វើឡើងក្រោមម្លប់ដើមឈើ ឬទីជម្រកក្រោមពន្លឺព្រះអាទិត្យផ្សេងទៀត ដរាបណាផ្នែកចំហៀងនៃម្លប់ដើមឈើឬទីជម្រកក្រោមពន្លឺព្រះអាទិត្យមិន ត្រូវបានបិទ ហើយមានខ្យល់ចេញចូលពីខាងក្រៅគ្រប់គ្រាន់នៅក្នុងទីកន្លែង។ ទីធ្លាខាងក្រៅអគារ ឬរចនាសម្ព័ន្ធបណ្ដោះអាសន្នទាំងឡាយដែលត្រូវបានប្រើសម្រាប់ប្រតិបត្តិការខាងក្រៅអគារ ត្រូវតែអនុលោមតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋសម្រាប់ទីកន្លែងខាងក្រៅអគារ ដូចបានបញ្ជាក់នៅក្នុងការណែនាំចាំបាច់របស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California ស្ដីពីការប្រើប្រាស់រចនាសម្ព័ន្ធបណ្ដោះអាសន្នសម្រាប់ប្រតិបត្តិការអាជីវកម្មខាងក្រៅអគារ។
- ☐ រចនាសម្ព័ន្ធខាងក្រៅអគារដែលមិនឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋសម្រាប់ទីកន្លែងខាងក្រៅអគារ ត្រូវបានចាត់ទុកថាជាទីកន្លែងខាងក្នុងអគារ ហើយអតិថិជនដែលនៅក្នុងនោះនឹងត្រូវបានរាប់ចំនួន និងរាប់បញ្ចូលជាផ្នែកនៃដែនកំណត់ចំនួនមនុស្សខាងក្នុងអគារសរុប 50%។
- ☐ បុគ្គលិកត្រូវតែត្រួតពិនិត្យការចូលរបស់ភ្ញៀវឲ្យបានតឹងរ៉ឹងនិងជាបន្តបន្ទាប់នៅគ្រប់ច្រកចូលទាំងអស់មកកាន់ទីកន្លែងខាងក្នុង និងខាងក្រៅអគារនៃកន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណដើម្បីតាមដានចំនួនមនុស្ស និងធានាបាននូវការអនុលោមតាមដែនកំណត់ចំនួនមនុស្ស និងល័ក្ខខ័ណ្ឌតម្រូវនៃការរក្សាគំលាតរាងកាយ។ កន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណអាចជ្រើសរើសដាក់កម្រិតលើចំនួនច្រកចូលដែលបើកសម្រាប់សាធារណៈជនក្នុងអំឡុងម៉ោងធ្វើការធម្មតា ដើម្បីសម្រួលដល់ការតាមដានកាន់តែងាយស្រួល។ កន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណដែលត្រួតពិនិត្យមិនបានគ្រប់គ្រាន់ ឬមិនត្រួតពិនិត្យ ឬមើលទៅដូចជាផ្ទុកមនុស្សលើសចំណុះ អាចត្រូវបានបិទទ្វារជាបណ្ដោះអាសន្នតាមការសម្រេចរបស់អធិការកិច្ចសុខភាពសាធារណៈរហូតដល់បញ្ហាទាំងនេះត្រូវបានកែតម្រូវដូចបានកំណត់ដោយអធិការកិច្ចសុខភាពនៅនឹងកន្លែង។

- ❑ ចៀសវាងការឲ្យអតិថិជនតម្រង់ជួរនៅខាងក្រៅទីកន្លែង និងពិចារណាចាត់តាំងបុគ្គលិកម្នាក់នៅច្រកចូលនៃកន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណ ដើម្បីជួយរក្សាកម្រិតចំនួនមនុស្ស។
- ❑ មានតែអតិថិជនដែលកំពុងហាត់ប្រាណជាក់ស្តែងប៉ុណ្ណោះ ទើបគួរស្ថិតនៅទីកន្លែងហាត់ប្រាណអគារ។
- ❑ បុគ្គលិក និងអតិថិជនទាំងអស់ដែលនៅកន្លែងហាត់ប្រាណខាងក្នុងឬខាងក្រៅអគារត្រូវពាក់ម៉ាស់គ្រប់ពេលវេលា លើកលែងតែពេលផឹកទឹក នៅក្នុងបន្ទប់សូណា/ចំហុយ ឬបន្ទប់ងូតទឹក។
- ❑ ថ្នាក់ហ្វឹកហ្វឺនជាក្រុមដូចជាអែរ៉ូប៊ិក យ៉ូហ្គា និងការរាំគួរតែធ្វើឡើងនៅខាងក្រៅអគារឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន និងគួរតែត្រូវបានកែប្រែដើម្បីដាក់កម្រិតទំហំថ្នាក់ ដើម្បីធានាបាននូវគំលាតរាងកាយយ៉ាងតិចប្រាំមួយហ្វីត រវាងអតិថិជន។
  - ○ ថ្នាក់ហាត់ប្រាណជាក្រុមអាចផ្តល់លុះត្រាតែអាចរក្សាគំលាតបាន និងមិនមានការប៉ះពាល់រវាងមនុស្សនិងមនុស្សប៉ុណ្ណោះ។
  - ○ សម្រាប់ថ្នាក់អែរ៉ូប៊ិកកម្រិតខ្ពស់ ដូចជាអែរ៉ូប៊ិក បង្វិល ឬការមានល័ក្ខខ័ណ្ឌ ឬប្រើម៉ាស៊ីនដូចជាម៉ាស៊ីនជាន់ឆ្លាស់ (elliptical) ម៉ាស៊ីនរត់ឬជាន់ ចូរពិចារណាដាក់បុគ្គលនិងឧបករណ៍ឲ្យឃ្លាតពីគ្នាយ៉ាងតិច 8 ហ្វីតជំនួសឲ្យ 6 ហ្វីត។
- ❑ ទីលានលេងកីឡាខាងក្រៅអគារ អាចត្រូវបានប្រើសម្រាប់ការអនុវត្តបុគ្គល ឬសម្រាប់សកម្មភាពដែលអាចរក្សាគំលាតរាងកាយ 6 ហ្វីតនៅក្នុងសកម្មភាពទាំងមូល។ នៅពេលដែលមនុស្សកំពុងរង់ចាំប្រើទីលាន គួរអនុវត្តដែនកំណត់ពេលវេលាអតិបរមាសម្រាប់ការប្រើប្រាស់ទីលានដោយអ្នកចូលរួមនីមួយៗ។ អ្នកចូលរួមដែលរង់ចាំ ត្រូវតែអនុវត្តការរក្សាគំលាតរាងកាយ។
- ❑ ថ្នាក់យ៉ូហ្គាដែលធ្វើឡើងនៅក្នុងសីតុណ្ហភាពខ្ពស់ជាង 100° F គួរត្រូវបានរារាំង។
- ❑ គ្រូបង្វឹកផ្ទាល់ខ្លួនត្រូវបានអនុញ្ញាត បើសិនជាពួកគេរក្សាគំលាតប្រាំមួយហ្វីតពីអតិថិជននិងពាក់ម៉ាស់។ អតិថិជនត្រូវតែពាក់ម៉ាស់ ខណៈពេលទទួលការបង្រៀន និងគួរត្រូវបានរំលឹកឲ្យហាត់ប្រាណក្នុងកម្រិតដែលពួកគេអាចដកដង្ហើមបានស្រួល ខណៈពេលពាក់ម៉ាស់លើច្រមុះ និងមាត់របស់ពួកគេនៅគ្រប់ពេលវេលាប៉ុណ្ណោះ។
- ❑ ឧបករណ៍ត្រូវបានដាក់ឲ្យឃ្លាតពីគ្នាយ៉ាងតិច 6 ហ្វីត ដោយមានគំលាតកាន់តែឆ្ងាយសម្រាប់ម៉ាស៊ីនរត់ និងឧបករណ៍ហាត់ប្រាណដែលបញ្ចេញកម្លាំងខ្លាំងផ្សេងទៀត។ ឧបករណ៍អាចត្រូវបានរៀបចំជាលំនាំអក្សរ "X" ដើម្បីផ្តល់ជូននូវគំលាតកាន់ តែឆ្ងាយ។ ឧបករណ៍ដែលមិនអាចផ្លាស់ទីបានត្រូវបានគូសសម្គាល់ដើម្បីធានាថាអតិថិជនអាចរក្សាគំលាតយ៉ាងតិចប្រាំ មួយ (6) ហ្វីតពីគ្នា។ បង់ស្អិតឬការសម្គាល់ផ្សេងទៀតជួយឲ្យអតិថិជនរក្សាគំលាត 6 ហ្វីតពីគ្នានិងពីអ្នកដទៃនៅក្នុងជួរ ផ្សេងៗ។ ការសម្គាល់ច្បាស់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនដែលមកដល់នៅក្នុងជួរ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលរង់ចាំផ្សេងទៀតដែលចូលតម្រង់ជួរ។
- ❑ ប្រើប្រាស់លំនាំចរាចរណ៍ថ្មើរជើងតែមួយផ្លូវនៅក្នុងទីកន្លែងហាត់ប្រាណខាងក្រៅអគារ ដោយមានតម្រុយនិងសញ្ញាជារូបភាព។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិចប្រាំមួយ (6) ហ្វីតពីអតិថិជន និងពីបុគ្គលិកដូចគ្នានៅគ្រប់កន្លែងទាំងអស់នៃកន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណ។ បុគ្គលិកអាចមកជិតជាបណ្តោះអាសន្ន នៅពេលចាំបាច់ដើម្បីទទួលយកការបង់ប្រាក់ បញ្ជូនទំនិញ ឬសេវាកម្ម ឬទៅតាមការចាំបាច់។
- ❑ សេវាកម្មម៉ាស្សាត្រូវបានអនុញ្ញាត និងត្រូវបានតម្រូវឲ្យអនុលោមតាមផ្នែកដែលពាក់ព័ន្ធនៃពិធីការសម្រាប់ [សេវាកម្មថែទាំផ្ទាល់ខ្លួន]() ដែលបានចុះផ្សាយ។
- ❑ បន្ទប់ទឹក បន្ទប់ផ្លាស់ទឹក និងទូដាក់សម្ភារៈដែលស្ថិតនៅខាងក្នុងទីកន្លែងអាចត្រូវបានបើកទ្វារសម្រាប់ឲ្យអតិថិជនប្រើប្រាស់ដោយដាក់កម្រិតលើចំនួន50%នៃទីតាំង ។
- ❑ សញ្ញា និងការសម្គាល់លើកម្រាលឥដ្ឋ គួរត្រូវបានប្រើដើម្បីធានាបាននូវការរក្សាគំលាតរាងកាយសមស្របខណៈពេលអតិថិជនស្ថិតនៅក្នុងទូដាក់សម្ភារៈ។
- ❑ ទីកន្លែងដែលមានបន្ទប់ទឹកប្រើរួមគ្នា គួរត្រូវបានសម្អាត ជាប្រចាំពេញមួយថ្ងៃដោយប្រើសារធាតុសម្លាប់មេរោគដែលបានចុះបញ្ជីជាមួយ EPA។ ផ្ទៃដែលមានការប៉ះពាល់ច្រើនដូចជាក្បាលរ៉ូប៊ីណេ បង្គន់ ដៃទ្វារ និងកុងតាក់ភ្លើងត្រូវតែសម្អាតនិងសម្លាប់មេរោគឲ្យបានញឹកញាប់យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ប៉ុន្តែញឹកញាប់ជាងនេះបើចាំបាច់។
- ❑ បង្កើតនិងបិទផ្សាយកាលវិភាគសម្អាតសម្រាប់ទីកន្លែងបន្ទប់ទឹក។ ចូរប្រាកដថាបិទបន្ទប់ទឹកក្នុងអំឡុងដំណើរការសម្អាតនិងសម្លាប់មេរោគ។
- ❑ ពិចារណាប្រើបញ្ជីត្រួតពិនិត្យ ឬប្រព័ន្ធសវនកម្មដើម្បីធ្វើការតាមដានថាតើការសម្អាតត្រូវបានធ្វើឡើងញឹកញាប់ប៉ុណ្ណា។
- ❑ ធ្វើឲ្យប្រាកដថាបរិក្ខារអនាម័យដំណើរការល្អធម្មតា និងមានស្តុកនៅគ្រប់ពេលវេលា។ ផ្តល់សាប៊ូ ក្រដាសជូត និងទឹកអនាម័យលាងដៃបន្ថែមនៅពេលចាំបាច់។ ដំឡើងឧបករណ៍ដែលមិនបាច់ប៉ះ បើអាចធ្វើបាន ដែលរួមមានដូចជាក្បាលរ៉ូប៊ីណេកន្ទន់ដែលមានសិនស័រចាប់ចលនា ឧបករណ៍បញ្ចេញសាប៊ូ ឧបករណ៍បញ្ចេញទឹកអនាម័យលាងដៃ និង

ឧបករណ៍បញ្ចេញក្រដាសជូត។

- ❑ ពិចារណាកែប្រែទ្វារទៅកាន់បន្ទប់ទឹករួម ដើម្បីឲ្យអាចបើកនិងបិទដោយមិនបាច់ប៉ះដៃទ្វារ ដោយប្រើឧបករណ៍បើក ឬឧបករណ៍បញ្ជាបើកទ្វារដោយដៃនៅគ្រប់ពេលដែលអាចធ្វើបាន។ បើសិនជាគេមិនអាចបើកទ្វារ ដោយមិនប៉ះដៃទ្វារ ឬឧបករណ៍បញ្ជាដោយដៃ ចូរដាក់ធុងសម្រាមមួយនៅជិតទ្វារនោះដើម្បីធានាថាគេអាចបោះចោលក្រដាសជូតបានយ៉ាងងាយនៅពេលបញ្ជាទ្វារ។ ទីតាំងនិងកន្លែងដាក់ធុងសម្រាមមិនគួរធ្វើឲ្យរាំងស្ទះដល់ច្រកចេញ ការជម្លៀសខ្លួនបរិក្ខារ សង្គ្រោះបន្ទាន់ ឬការសម្រួលសមហេតុផលណាមួយដែលបានផ្តល់ជូនក្រោមច្បាប់ស្តីពីជនជាតិអាមេរិកាំងដែលមានពិការភាព។
- ❑ ផ្តល់ព័ត៌មានអំពីរបៀបលាងដៃឲ្យបានសមស្រប រួមទាំងការព្យួរសញ្ញានៅក្នុងបន្ទប់ទឹកផងដែរ។
- ❑ ពិចារណាផ្អាកសកម្មភាពមិនសំខាន់ ដូចជាប្រតិបត្តិការលក់រាយ ការថែទាំកុមារ និងសេវាកម្មម្ហូបអាហារ។ បើសិនជាទីកន្លែងហាត់ប្រាណផ្តល់ការកម្សាន្តបែបនោះ ពួកគេគួរពិនិត្យមើលនិងអនុវត្តតាមពិធីការសុខភាពសាធារណៈនៃខោនធីដែលបានចុះផ្សាយសម្រាប់សកម្មភាពទាំងនេះ។
- ❑ ទីកន្លែងហែលទឹកនៅក្នុងកន្លែងហាត់ប្រាណក៏ត្រូវអនុវត្តតាម[ពិធីការខោនធីសម្រាប់អាងហែលទឹកសាធារណៈ]ផងដែរ។ អាងទឹកក្តៅខាងក្នុងអគារ សូណា និងបន្ទប់ស្ទីមបន្តបិទទ្វារដដែល។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ប្រព័ន្ធ HVAC គឺស្ថិតក្នុងសភាពដំណើរការល្អ ដល់កម្រិតអតិបរមា ដែលអាចធ្វើឲ្យខ្យល់ចេញចូលត្រូវបានបង្កើនឡើង។ ខ្យល់ចេញចូលដែលមានប្រសិទ្ធភាព គឺជាវិធីដ៏សំខាន់បំផុតមួយដើម្បីគ្រប់គ្រងការចម្លងតាមអ៊ែរ៉ូសូល (aerosol) តូចៗ។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅនិងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។ មើល[សេចក្តីណែនាំបណ្តោះអាសន្នរបស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California សម្រាប់ការបញ្ចេញបញ្ចូលខ្យល់ ការច្រោះ និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុងអគារ] សម្រាប់ព័ត៌មានលម្អិត។
  - ○ សូមកត់សម្គាល់៖ ការកែលម្អខ្យល់ចេញចូល និងការកែលម្អគុណភាពខ្យល់ខាងក្នុងអគារផ្សេងៗទៀត គឺជាការបំពេញបន្ថែម និងមិនមែនជាការជំនួសឲ្យការការពារដែលចាំបាច់ ដូចជាការពាក់ម៉ាស់ (លើកលែងនៅក្នុងបរិយាកាសដែលមានបរិក្ខារបន្ថែម ដែលតម្រូវឲ្យមានការការពារផ្លូវដង្ហើមសមស្រប) ការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នា ការលាងដៃឲ្យបានញឹកញាប់ និងការដាក់កម្រិតសកម្មភាពដែលនាំមនុស្សមកពីគ្រួសារខុសៗគ្នាឲ្យមកជួបជុំគ្នា។
- ❑ ភ្ញៀវទាំងអស់ត្រូវបានតម្រូវឲ្យពាក់ម៉ាស់ ខណៈដែលពួកគេស្ថិតនៅកន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណ។ ករណីលើកលែងតែមួយគត់គឺនៅពេលភ្ញៀវកំពុងហែលទឹកនៅក្នុងអាង==នៅក្នុងបន្ទប់សូណា/ចំហុយ ឬបន្ទប់ងូតទឹក==។ នេះអនុវត្តចំពោះមនុស្សពេញវ័យទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់ម៉ាស់ដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួន ត្រូវតែពាក់សន្ទះបាំងមុខដែលមានក្រណាត់រំពឹងទុកខាងក្រោមដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ បើសិនជាល័ក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់បិទដែលមានទម្រង់រឹតតឹងនឹងចង្កា។ មិនត្រូវប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវឡើយ។ ម៉ាស់ត្រូវបានតម្រូវសូម្បីអំឡុងពេលប្រើប្រាស់កម្លាំងខ្លាំងតាមការទ្រាំបានក៏ដោយ។
- ❑ ភ្ញៀវគួរត្រូវបានរំលឹកឲ្យដាក់កម្រិតការបញ្ចេញកម្លាំងរបស់ខ្លួនត្រឹមកម្រិតមួយដែលមានផាសុខភាពខណៈពេលពាក់ម៉ាស់ និងសម្រាកឲ្យបានញឹកញាប់ពីការហាត់ប្រាណ បើសិនជាពួកគេចាប់ផ្តើមមានការលំបាកក្នុងការដកដង្ហើម។ គេគួរផ្លាស់ប្តូរម៉ាស់បើសិនជាវាសើម ស្អិតជាប់នឹងមុខរបស់មនុស្ស ឬរាំងដល់ការដកដង្ហើម។ ដើម្បីគាំទ្រសុវត្ថិភាពបុគ្គលិករបស់អ្នកនិងភ្ញៀវផ្សេងទៀត ម៉ាស់គួរត្រូវបានផ្តល់ឲ្យភ្ញៀវដែលមកដល់ដោយមិនមានវា។
- ❑ ការត្រួតពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចនឹងចូលក្នុងទីកន្លែង។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម អការគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងទៀត ដូចជាការចុះឈ្មោះចូលតាមអនឡាញ ឬតាមរយៈ[ស្លាកសញ្ញា]ដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថា ភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
  - ○ ការត្រួតពិនិត្យអវិជ្ជមាន (មិនមានបញ្ហា)។ បើសិនជាបុគ្គលគ្មានរោគសញ្ញា និងមិនមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលធ្វើការសម្រាប់ថ្ងៃនោះបាន។
  - ○ ការត្រួតពិនិត្យវិជ្ជមាន (មានបញ្ហា)៖

  - បើសិនជាបុគ្គលរូបនោះមានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលគេបានស្គាល់ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូល ឬធ្វើការនៅកន្លែងជាក់ស្តែងបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ពីគេនៅផ្ទះ។ ចូរផ្តល់ការណែនាំអំពីការនៅដាច់ពីគេដល់ពួកគេដែលអាចរកបាននៅ ph.lacounty.gov/covidquarantine ។
  - បើសិនជាបុគ្គលរូបនោះកំពុងចេញរោគសញ្ញាណាមួយដែលបានកត់សម្គាល់ខាងលើ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ពួកគេមិនអាចចូល ឬធ្វើការនៅកន្លែងជាក់ស្តែងបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ចូរផ្តល់ឲ្យពួកគេនូវការណែនាំអំពីការនៅដាច់ដោយឡែកដែលអាចរកបាននៅ ph.lacounty.gov/covidisolation ។

❑ ប្រព័ន្ធបង់ប្រាក់ និងចុះឈ្មោះចូលដោយមិនបាច់ប៉ះ គឺមានសម្រាប់ឲ្យប្រើ ឬបើមិនអាចធ្វើបាន ប្រព័ន្ធទាំងនេះត្រូវបានធ្វើអនាម័យយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ ពិពណ៌នា៖

________________________________________________________________________

❑ ធ្វើការសម្អាតយ៉ាងល្អិតល្អន់ពេញមួយថ្ងៃនៅតាមទីកន្លែងដែលមានមនុស្សចេញចូលច្រើននៅក្នុងសាលហាត់ប្រាណ ឬអាជីវកម្មហាត់ប្រាណដែលអាចនឹងត្រូវបានប្រើដោយបុគ្គលិក ដូចជាបន្ទប់សម្រាក ក៏ដូចជាកន្លែងចូលនិងចេញ ដូចជាជណ្តើរ ផ្លូវមុខជណ្តើរ ជណ្តើរយន្ត បង្កាន់ដៃ និងប៊ូតុងបញ្ជាជណ្តើរយន្ត។

❑ សម្លាប់មេរោគផ្ទៃដែលបានប្រើជាទូទៅឲ្យបានញឹកញាប់ ដែលរួមមានម៉ាស៊ីន និងឧបករណ៍ហាត់ប្រាណផ្ទាល់ខ្លួន ដៃទ្វារ និងទីកន្លែងលាងដៃ។

❑ តម្រូវឲ្យអតិថិជនសម្លាប់មេរោគឧបករណ៍ កម្រាល និងម៉ាស៊ីនហាត់ប្រាណផ្ទាល់ខ្លួនមុននិងក្រោយពីប្រើប្រាស់ដោយប្រើក្រដាសជូតសម្លាប់មេរោគដែលបានផ្តល់ឲ្យ។ ធ្វើឲ្យប្រាកដថា មានធុងសម្រាមដែលបានតម្រៀបជាជួរ មិនបាច់ប៉ះនៅក្នុងទីកន្លែងហាត់ប្រាណទាំងមូល ដើម្បីបោះចោលក្រដាសជូតដែលបានប្រើរួច។

  - បើសិនជាសមាជិកមិនអាច ឬមិនព្រមជូត/សម្លាប់មេរោគឧបករណ៍បន្ទាប់ពីហាត់ប្រាណ ចូរផ្តល់ស្លាក "រួចរាល់ដើម្បីសម្អាត" (ready to clean) សម្រាប់ឲ្យសមាជិកដាក់នៅលើឧបករណ៍បន្ទាប់ពីប្រើរួច ដើម្បីធ្វើឲ្យប្រាកដថា ឧបករណ៍ត្រូវបានសម្លាប់មេរោគដោយបុគ្គលិក មុនពេលប្រើប្រាស់លើកក្រោយ។

❑ ធ្វើឲ្យប្រាកដថាបុគ្គលិកទាំងអស់ត្រូវបានបណ្តុះបណ្តាលឲ្យប្រើប្រាស់ និងមានការផ្គត់ផ្គង់គ្រប់គ្រាន់នូវផលិតផលសម្អាត និងសម្លាប់មេរោគគ្រប់មុខងារ នៅពេលចាំបាច់ ស្របតាមសេចក្តីតម្រូវរបស់ Cal/OSHA និងការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់ដែលមានសុវត្ថិភាព និងឧបករណ៍ការពារផ្ទាល់ខ្លួនដែលចាំបាច់សម្រាប់ផលិតផលសម្អាត។

❑ បុគ្គលិកគួរមានខ្យល់ចេញចូល (លំហូរខ្យល់) គ្រប់គ្រាន់នៅក្នុងទីកន្លែងដែលពួកគេកំពុងសម្លាប់មេរោគ។

❑ គ្រឿងបរិក្ខារអនាម័យគឺមានសម្រាប់ឲ្យបុគ្គលិកប្រើប្រាស់តែប៉ុណ្ណោះ។ ធ្វើឲ្យប្រាកដថាគ្រឿងបរិក្ខារអនាម័យអាចធ្វើប្រតិបត្តិការបាន និងមានស្តុកគ្រប់ពេលវេលា។ ផ្តល់សាប៊ូ ក្រដាសជូត និងទឹកអនាម័យលាងដៃបន្ថែមនៅពេលចាំបាច់។ បើអាចធ្វើបាន ចូរដំឡើងឧបករណ៍ដែលមិនបាច់ប៉ះ ដូចជាក្បាលរ៉ូប៊ីណេចាប់សិនស័រចលនា ឧបករណ៍បញ្ចេញសាប៊ូ ឧបករណ៍បញ្ចេញទឹកអនាម័យលាងដៃ និងឧបករណ៍បញ្ចេញក្រដាសជូត។

❑ ធ្វើឲ្យប្រាកដថាធុងសម្រាមត្រូវបានចាក់ចេញជាប្រចាំ។

❑ គេគួរលើកអតិថិជនឲ្យត្រឡប់កាតប្រាំមួយហ្វីតពីបុគ្គលិកសម្អាត ឬបុគ្គលិកថែទាំ។ អនុវត្តដំណើរការដើម្បីចុះឈ្មោះចូលយ៉ាងឆាប់រហ័សជាមួយបុគ្គលិក ដើម្បីធានាថាភ្ញៀវកំពុងអនុវត្តតាមពិធីការនេះ។ ធ្វើឲ្យប្រាកដថាបុគ្គលិកអាចចែករំលែកព័ត៌មានទាំងនោះដោយមិនមានការភ័យខ្លាចពីផ្លូវច្បាប់ ឬសងសឹក។

❑ ពិចារណាអនុវត្តប្រព័ន្ធចុះឈ្មោះចេញ (check-out) សម្រាប់ឲ្យអតិថិជនប្រើប្រាស់ឧបករណ៍ និងគ្រឿងតូចៗណាមួយ (ឧ. ខ្សែពួរហាត់ប្រាណ ខ្សែលោត កម្រាល ប្រដាប់រំកិលធ្វើពីហ្វូម ។ល។)។ បង្កើតដំណើរការមួយដើម្បីសម្អាត និងសម្លាប់មេរោគវត្ថុទាំងនេះបន្ទាប់ពីត្រឡប់មកវិញ។

❑ អតិថិជនត្រូវបានលើកទឹកចិត្តឲ្យយកដបទឹករបស់ខ្លួនមកជាមួយ។ លើកទឹកចិត្តឲ្យអតិថិជនយកកន្សែង និងកម្រាលរបស់ខ្លួនមកជាមួយ និងពិចារណាសោយការផ្តល់កន្សែងដែលផ្តល់ដោយទីកន្លែង ឬផលិតផលអនាម័យផ្ទាល់ខ្លួនផ្សេងៗ។

❑ សម្រាប់កន្សែង ក្រណាត់ជូត ឬវត្ថុដែលបានបោកគក់ផ្សេងៗ ចូរផ្តល់ឧបករណ៍ផ្ទុកបិទជិតដែលអតិថិជនអាចដាក់កន្សែងឬវត្ថុផ្សេងៗទៀតដែលបានប្រើរួច។ ធ្វើឲ្យប្រាកដថាវត្ថុទាំងនោះមិនអាចប្រើម្តងទៀតបានលុះត្រាតែបានបោកគក់សមស្របដោយសេវាកម្មបោកគក់អាជីវកម្ម ឬដំណើរការបោកគក់នៅក្នុងកន្លែង។ ផ្ទុកក្រណាត់ស្អាតនៅក្នុងកន្លែងដែលត្រូវបានគ្របត្រឹមត្រូវ។ ធ្វើឲ្យប្រាកដថាបុគ្គលិកចាត់ចែងក្រណាត់កខ្វក់ ឬបោកគក់ពាក់ស្រោមដៃ។

  - មានបុគ្គលិកម្នាក់ផ្តល់ក្រណាត់ ឬសម្ភារផ្សេងទៀតទៅតាមសំណើជាជាងការរៀបចំកន្លែងដែលចាប់យកដោយ

ខ្លួនឯង។

- ❑ គ្រឿងកម្សាន្ត ដូចជាទស្សនាវដ្តី សៀវភៅ កន្លែងយកទឹកដោយខ្លួនឯង (លុះត្រាតែមិនបាច់ប៉ះ) និងវត្ថុផ្សេងទៀតសម្រាប់អតិថិជន ត្រូវតែយកចេញពីទីកន្លែងទាំងអស់។
- ❑ នៅពេលជ្រើសរើសសារធាតុគីមីសម្រាប់សម្អាត និយោជកគួរប្រើផលិតផលដែលបានអនុម័តឲ្យប្រើប្រាស់ប្រឆាំងនឹងជំងឺ COVID-19 នៅលើបញ្ជីដែលបានអនុម័តរបស់ភ្នាក់ងារការពារបរិស្ថាន (EPA) និងអនុវត្តតាមការណែនាំរបស់ផលិតផល។ ប្រើប្រាស់សារធាតុសម្លាប់មេរោគដែលបានសរសេរថាមានប្រសិទ្ធភាពប្រឆាំងនឹងភ្នាក់ងារមេរោគ សូលុយស្យុងធ្វើឲ្យស (Bleach) នៅតាមផ្ទះដែលបានពង្រាវ (5 ស្លាបព្រាក្នុងទឹកមួយហ្គាឡុង) ឬសូលុយស្យុងអាល់កុលដែលមានជាតិអាល់កុលយ៉ាងតិច 60% ដែលសមស្របសម្រាប់ផ្ទៃ។ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអំពីការណែនាំរបស់ក្រុមហ៊ុនផលិត និងសេចក្តីតម្រូវរបស់ Cal/OSHA សម្រាប់ការប្រើប្រាស់ដែលមានសុវត្ថិភាព។ បុគ្គលិកដែលប្រើផលិតផលសម្អាត ឬសារធាតុសម្លាប់មេរោគ គួរតែពាក់ស្រោមដៃ និងឧបករណ៍ការពារផ្សេងទៀតដូចបានតម្រូវដោយផលិតផល។ អនុវត្តតាមវិធីសាស្ត្រសម្អាតដែលមានសុវត្ថិភាពសម្រាប់អ្នកជំងឺហឺត ដែលបានណែនាំដោយនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California។
- ❑ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់សាធារណជននៅកន្លែងហាត់ប្រាណ/អាជីវកម្មហាត់ប្រាណខាងក្រៅអគារ។ ពិចារណារៀបចំទីកន្លែងលាងដៃយ៉ាងតិចបំផុតមួយដែលអាចប្រើបានសម្រាប់បុគ្គលិក និងអតិថិជននៅទីកន្លែងខាងក្រៅអគារ។
- ❑ ស្រេចចិត្ត - ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត (ឧ. ការផ្តល់ម៉ោងធ្វើការសម្រាប់ជនចាស់ជរា)៖

______________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណជន

- ❑ ច្បាប់ចម្លងនៃពិធីការនេះ ឬវិញ្ញាបនបត្របញ្ជាក់ការអនុវត្តតាមវិធានសុវត្ថិភាពជំងឺ COVID-19 ខោនធី Los Angeles របស់អាជីវកម្ម ត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងកន្លែង។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់ពីការអនុវត្តតាមវិធានសុវត្ថិភាពជំងឺ COVID-19 សូមចូលទៅកាន់ http://publichealth.lacounty.gov/eh/covid19cert.htm ។ ទីកន្លែងត្រូវតែរក្សាច្បាប់ចម្លងនៃពិធីការនេះនៅនឹងកន្លែងសម្រាប់ការត្រួតពិនិត្យឡើងវិញនៅពេលមានការស្នើសុំ។
- ❑ ស្លាកសញ្ញានៅច្រកចូលដែលអតិថិជនតម្រង់ជួរ និងទីតាំងដែលអាចមើលឃើញច្បាស់ ដែលជូនដំណឹងដល់បុគ្គលិក និងអតិថិជនពីដែនកំណត់នៃចំនួនអតិថិជន សេចក្តីតម្រូវឲ្យរក្សាគំលាតសង្គម និងបញ្ជាក់ថាម៉ាស់គឺចាំបាច់នៅគ្រប់ពេលវេលាលើកលែងតែនៅក្នុងអាងហែលទឹក។ ស្លាកសញ្ញាគួររំលឹកអតិថិជនកុំឲ្យហាត់ហួសកម្លាំង ខណៈដែលពាក់ម៉ាស់ និងហាត់ប្រាណ។ មើលគេហទំព័រការណែនាំជំងឺ COVID-19 របស់ DPH ក្នុងខោនធីសម្រាប់ធនធានបន្ថែម និងស្លាកសញ្ញាគំរូដែលអាជីវកម្មអាចប្រើប្រាស់បាន។
- ❑ ច្រកអនឡាញនៃអាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកហាង ការតម្រូវឲ្យប្រើម៉ាស់ ការធ្វើប្រតិបត្តិការខាងក្រៅអគារ ចំនួនអតិថិជនដែលបានកំណត់ គោលការណ៍ទាក់ទងនឹងការកក់ទុកជាមុន ការបង់ប្រាក់ជាមុន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជន ត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានសេវាកម្មសម្រាប់អតិថិជនដែលមានការលំបាកក្នុង ការផ្លាស់ទី និង/ឬដែលមានហានិភ័យ (risk) ខ្ពស់នៅទីសាធារណៈ។
  - ○ ពិចារណាអនុវត្តម៉ោងពិសេសដែលបានកំណត់សម្រាប់ប្រជាជនដែលមានហានិភ័យ (risk) ខ្ពស់ ឬងាយរងគ្រោះផ្នែកវេជ្ជសាស្ត្រ រួមមានជនចាស់ជរាដែលចូលបានដោយមានការកក់ទុកជាមុនប៉ុណ្ណោះ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

ឈ្មោះទំនាក់ទំនងអាជីវកម្ម៖ ______________________________

លេខទូរសព្ទ៖ ______________________________

កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖ ______________________________

ច្បាប់ចម្លង - មិនមានប្រសិទ្ធភាពទេ